# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ
នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
លេខៈ ១៨១.......សហអ

## សូមគោរពជូន
## ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

កម្មវត្ថុ ៖ របាយការណ៍នៃកិច្ចប្រជុំរវាង នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ DICO និង ភ្នាក់ងារអនុវត្ត IAs ប្រចាំខែកក្កដា

យោង៖ លិខិតអញ្ជើញលេខ ១៦៣ ពណ-សហអ ចុះថ្ងៃទី២៤ កក្កដា ២០១២

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាបនិងរាយការណ៍ជូនឯកឧត្តមទេសរដ្ឋមន្ត្រី មេត្តាជ្រាបថា ៖ កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១២ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិបានរៀបចំកិច្ចប្រជុំប្រចាំខែជាមួយ ភ្នាក់ងារអនុវត្តគម្រោង ដើម្បីជម្រុញការអនុវត្តន៍គម្រោង TDSP ។ ខ្ញុំបាទសូមអនុញ្ញាតរាយការណ៍ជូននូវចំណុចសំខាន់ៗដូចខាងក្រោម ៖

**១ -វឌ្ឍនៈភាពនៃការអនុវត្តន៍គម្រោងTDSP**

- នៅក្នុងឆមាសទី១ ដើមឆ្នាំ ២០១២ យើងបានធ្វើការចំណាយចំនួន $1,298,639ធៀបទៅនឹងថវិកាដែលបានបែងចែកប្រចាំត្រីមាស។ ចំពោះថវិកាគម្រោង TDSP សរុបមានចំនួន $12.35m ដែលគិតត្រឹមថ្ងៃទី៣០ មិថុនា២០១២ យើងបានចំណាយអស់ $3,705,724 ស្មើនឹង 30% ។ សម្រាប់ពេលខាងមុខមានគម្រោងត្រូវចំណាយតាមរយៈ MOU ទាំងអស់រួមទាំងគម្រោង ASYCUDA របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករដែលមានទឹកប្រាក់ចំនួន $6,934,799 ស្មើនឹង 55.5% និងចំណាយប្រតិបត្តិការលេខាធិការដ្ឋាន DICO មានទឹកប្រាក់ចំនួន $750,000 ស្មើនឹង 6.1% និង ចំណាយសម្រាប់ទីប្រឹក្សា ICT និង WTO មានទឹកប្រាក់ចំនួន $350,000 ស្មើនឹង 2.8% ។ ដូច្នេះទឹកប្រាក់ដែលនៅសល់ចំនួន $609,477 ស្មើនឹង 5.6% រក្សាទុកសម្រាប់គម្រោងថ្មីៗ ។
- យោងតាមកិច្ចប្រជុំក្រុមការងារសេសស្តេម្តកាលពី ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ ២០១២ ដែលបានសម្រេចលើកយកគម្រោង ៤ គឺ ៖ Codex National Committee, លេខាធិការដ្ឋានគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា, G-PSF របស់សភាពាណិជ្ជកម្មកម្ពុជា និង គម្រោងរបស់ Trade Training & Research Facility at MoC យកទៅពិភាក្សានៅកិច្ចប្រជុំ IC ថ្ងៃទី០៣ ខែសីហា ២០១២ ។



3585
Aug 8/12